**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៨-០១៧-០៤០ ស.ស.ភ                    រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ មករា ឆ្នាំ២០១៧

## សេចក្តីជូនដំណឹង
## ស្តីពី
## ការជ្រើសរើសបុគ្គលិក

ធនាគារជាតិនៃកម្ពុជា សូមជម្រាបជូនដំណឹងដល់សាធារណជនឲ្យបានជ្រាបថា ធនាគារជាតិនៃកម្ពុជានឹងធ្វើការជ្រើសរើសបុគ្គលិកទាំងពីរភេទ ឲ្យចូលបម្រើការងារក្នុង **ក្របខ័ណ្ឌលេខាធិការ "គ"** ចំនួន **១៥រូប** តាមរយៈការប្រឡងប្រជែង។ បេក្ខជនត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម ៖

១- មានសញ្ជាតិខ្មែរ
២- អាយុចន្លោះពី ១៨ ទៅ ២៥ឆ្នាំ
៣- មានសញ្ញាបត្រ**ប្រកាសនីយបត្រជាន់ខ្ពស់បច្ចេកទេសធនាគារ** ចេញដោយមណ្ឌលសិក្សាបច្ចេកទេសធនាគារ
៤- មានចំណេះដឹងភាសាអង់គ្លេស និងកុំព្យូទ័រ
៥- មានកាយសម្បទាគ្រប់គ្រាន់ (វិញ្ញាបនបត្របញ្ជាក់ពីនាយកដ្ឋានពេទ្យការងារ)។

បេក្ខជនអាចមកទំនាក់ទំនងសាកសួរព័ត៌មានលម្អិតបន្ថែមទៀត នៅនាយកដ្ឋានបុគ្គលិកនៃធនាគារជាតិនៃកម្ពុជា ដែលមានទីតាំងនៅឡូតិ៍ ២២-២៤ តាមបណ្តោយមហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ចន្លោះពីម៉ោង ៨:០០ព្រឹក ដល់ម៉ោង ១៥:០០រសៀល រៀងរាល់ថ្ងៃធ្វើការ។

- កាលបរិច្ឆេទទទួលពាក្យប្រឡង ៖ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ
- កាលបរិច្ឆេទឈប់ទទួលពាក្យប្រឡង ៖ **ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៧** វេលាម៉ោង ១១ : ០០នាទីព្រឹក
- កាលបរិច្ឆេទ មុខវិជ្ជា និងទីកន្លែងប្រឡង ៖ ជូនដំណឹងពេលក្រោយ ។/.

**ត.ប.ទេសាភិបាល**
**អគ្គលេខាធិការ**

**ហ៊ាន គឹមស៊ឿន**